**MEDIA ADVISORY**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# លោកសុរិយា ប្រាសាទស៊ូប៊ៃឌី អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ចាប់ផ្តើមបំពេញបេសកកម្មស្វែងរកការពិតចុងក្រោយរបស់លោកនៅព្រះរាជាណាចក្រកម្ពុជា

ទីក្រុងហ្សឺណែវ/ រាជធានីភ្នំពេញ (១៣ មករា ២០១៥) - អ្នកជំនាញការសិទ្ធិមនុស្សអង្គការសហ ប្រជាជាតិ លោក សុរិយាប្រាសាទស៊ូប៊ៃឌីនឹងបំពេញទស្សនកិច្ចជា ផ្លូវការនៅ ព្រះរាជាណាចក្រ កម្ពុជា ចាប់ ពីថ្ងៃទី១៧ ដល់ថ្ងៃទី២៥ខែមករាឆ្នាំ២០១៥។ នេះគឺជាបេសកកម្មចុងក្រោយរបស់លោក ស៊ូប៊ៃឌី ក្នុងសមត្ថភាពរបស់លោកជាអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលលោកត្រូវបានតែងតាំងដោយ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

អ្នកជំនាញការរូបនេះមានប្រសាសន៍ថា៖"ដំណើរទស្សនកិច្ចរបស់ខ្ញុំមកកាន់ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃការវាយតម្លៃជារួមរបស់ខ្ញុំ អំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបច្ចុប្បន្ន"។ "នៅក្នុងដំណើរបេសកកម្ម ចុងក្រោយរបស់ខ្ញុំមកកាន់ព្រះរាជាណាចក្រកម្ពុជា ខ្ញុំនឹងផ្តោតលើវឌ្ឍនភាពដែលសម្រេចបាន ក្នុងការធ្វើឱ្យស្ថាប័នរដ្ឋទាំងឡាយមានភាពឯករាជ្យ ដែលសំដៅជាពិសេសដល់ការធ្វើកំណែទម្រង់ ច្បាប់និង ប្រព័ន្ធយុត្តិធម៌។"

លោក ស៊ូប៊ៃឌី បានគ្រោងជួបជាមួយលោកនាយករដ្ឋមន្ត្រី និងសមាជិកជាន់ខ្ពស់ដទៃទៀតរបស់រាជរដ្ឋាភិបាលនៅក្នុងអំឡុងពេលបំពេញបេសកកម្មរយៈពេលប្រាំបួនថ្ងៃរបស់លោក។ លោកនឹងជួបផងដែរជាមួយអ្នកការពារសិទ្ធិមនុស្ស តំណាងអង្គការសង្គមស៊ីវិល និងសហគមន៍ក៏ដូចជាជាមួយក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និងសហគមន៍ម្ចាស់ជំនួយ។

ចាប់តាំងពីលោកបានទទួលការតែងតាំងជាអ្នករាយការណ៍ពិសេសក្នុងខែមីនាឆ្នាំ ២០០៩ មក លោក ស៊ូប៊ៃឌី បានបំពេញទស្សនកិច្ចចំនួនដប់មួយលើកមកកាន់ព្រះរាជាណាចក្រកម្ពុជាគិតមកទល់ពេលនេះ ហើយបានបង្ហាញរបាយការណ៍ចំនួនប្រាំពីរជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

អ្នកជំនាញការឯករាជ្យបានបង្ហាញរបាយការណ៍ចុងក្រោយ* របស់លោកជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងខែកញ្ញាឆ្នាំ ២០១៤ ហើយនឹងត្រូវបញ្ចប់ពេញលេញនូវអាណត្តិការងារប្រាំមួយឆ្នាំរបស់លោកក្នុងមុខតំណែងនេះក្នុងខែមីនាឆ្នាំ ២០១៥ នៅពេលដែលអ្នកកាន់អាណត្តិការងារថ្មី នឹងត្រូវបានតែងតាំងចូលកាន់មុខតំណែងនេះ។

អ្នករាយការណ៍ពិសេស នឹងធ្វើ**សន្និសីទកាសែត** នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចរបស់លោក គឺនៅ**ថ្ងៃសុក្រ ទី២៣ ខែមករា នៅវេលាម៉ោង ៣ រសៀល** នៅការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (ការិយាល័យ OHCHR) ដែលមានអាស័យដ្ឋានផ្ទះលេខ១០ ផ្លូវ ៣០២ សង្កាត់បឹងកេងកង១ រាជធានីភ្នំពេញ។

**(*)** ដើម្បីមើលរបាយការណ៍ចុងក្រោយបំផុតរបស់អ្នករាយការណ៍(A/HRC/24/36) ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស សូមចូលទៅកាន់គេហទំព័រ
http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេស អ.ស.ប ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ និងជាមេធាវីអាជីពមួយរូប នៅចក្រភពអង់គ្លេស។ លោកសាស្ត្រាចារ្យ ស៊ូប៊ែឌី ក៏ជាអ្នកនិពន្ធរបស់ទស្សនាវដ្តីអាស៊ីផ្នែកនីតិអន្តរជាតិផងដែរ (បោះពុម្ពផ្សាយដោយការិយាល័យព័ត៌មាន នៃសាកលវិទ្យាល័យខេមប្រីដជ៍ និងជាអនុប្រធាននៃសង្គមអាស៊ីផ្នែកនីតិអន្តរជាតិ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ*
*http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx*

*អ្នករាយការណ៍ពិសេសគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយដែលមានអ្នកជំនាញការឯករាជ្យច្រើនរូប ក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើលនិងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់ប្រទេសមួយជាក់លាក់ ឬតាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ អ្នកជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សំរាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមក៖*
***នៅរាជធានីភ្នំពេញ៖** កញ្ញា ប៊ូស្រា រ៉ាម៉ាន់ តាមរយៈទូរស័ព្ទលេខ (+៨៥៥ ១២ ៧៩០ ១៧៨/ brahman@ohchr.org)*
***នៅទីក្រុងហ្សឺណែវ៖** កញ្ញា Olga Nakajo តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉េល onakajo@ohchr.org) ឬសរសេរមកកាន់ srcambodia@ohchr.org*

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមក ឈ្មោះ Xabier Celaya សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉ែល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្តាញព័ត៌មានសង្គម ៖**
**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គីល៖** Google+ gplus.to/unitednationshumanrights
**យូធូប៖** http://www.youtube.com/UNOHCHR
**បរិយាយសាច់រឿង៖** http://storify.com/UNrightswire

ឆែកមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖ http://uhri.ohchr.org/en